# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យអគ្គនាយកក្រសួងអប់រំ

**440 NORTH BROAD STREET – SUITE 301**

**PHILADELPHIA, PA 19130**

**WILLIAM R. HITE, JR., Ed.D.**
អគ្គនាយកក្រសួងអប់រំ

ទូរស័ព្ទ (២១៥) ៤០០-៤១០០
ទូរសារ (២១៥) ៤០០-៤១០៣

ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤

លិខិតជូនដំណឹងពីអគ្គនាយកក្រសួងអប់រំ William R. Hite៖

នៅតែបីសប្តាហ៍ទៀតដល់ថ្ងៃបើកសាលាហើយ ថ្ងៃនេះយើងត្រូវធ្វើការសម្រេចចិត្តដ៏ពិបាកដូចកាលពីមុន។ ដូចយើងខ្ញុំបានប្រកាសជាងមួយខែកន្លងទៅនេះ ថាយើងខ្វះប្រាក់ ៨១ លានដុល្លារ សម្រាប់ថវិការបស់យើងក្នុងឆ្នាំនេះ ដែលយើងត្រូវតម្រប់តាមរយៈប្រាក់ចំណូលបន្ថែម ឬ ត្រូវកាត់បន្ថយការចំណាយ។

ដើម្បីកាត់បន្ថយការរំខានដល់ក្រុមគ្រួសារ និង ដើម្បីអប់រំក្មេង យើងខ្ញុំបានសម្រេចចិត្តថាត្រូវកាត់បន្ថយការចំណាយមួយចំនួនទៀត ដែលពិបាកហើយសង្ឃឹមថា គឺជាការបណ្តោះអាសន្ន ដើម្បីបើកសាលាឲ្យបានទាន់ពេលវេលា។

ការសម្រេចចិត្តនេះគឺផ្តោតទៅលើផលលំបាកចំពោះសិស្សានុសិស្ស និងក្រុមគ្រួសារ បើសិនជាយើងមិនបានបើកសាលាឲ្យទាន់ពេលវេលាទេនោះ - ជាពិសេស គឺការបាត់បង់ម៉ោងសិក្សាសម្រាប់សិស្សានុសិស្ស។ ក្នុងនាមជាក្រសួងអប់រំ គោលការណ៍សំខាន់របស់យើងគឺផ្តល់ឱកាសឲ្យសិស្សានុសិស្សសិក្សាឲ្យបានច្រើន។ ការពន្យាពេលបើកសាលា ដូចជាការដាក់ទោសសិស្សានុសិស្សចំពោះការបរាជ័យរបស់មនុស្សពេញវ័យ - ក្នុងពេលជាមួយគ្នានោះ យើងនៅតែបង់ប្រាក់ខែឲ្យបុគ្គលិក បង់ប្រាក់ឲ្យសាលាឆាទ័រ ហើយបង់ថ្លៃឲ្យក្រុមហ៊ុនផ្សេងៗ ដែលធ្វើកិច្ចការឲ្យក្រសួង នៅពេលដែលសិស្សានុសិស្សមិនបានទទួលការអប់រំអ្វីទាំងអស់។

យើងខ្ញុំក៏គិតអំពីការពិតថា ការពន្យាពេលបើកសាលារហូតដល់ពេលដែលយើងដឹងច្បាស់លាស់អំពីប្រាក់ចំណូលបន្ថែម អាចធ្វើឲ្យមានការខ្វះខាតប្រាក់កាន់តែធ្ងន់ធ្ងរឡើង បើសិនជាសិស្សានុសិស្សជាច្រើនទៀតទៅរៀននៅសាលាឆាទ័រ។

ទីបំផុត យើងខ្ញុំបានពិចារណាដល់ការធានាអះអាងជាសាធារណដែលយើងបានទទួលពី អភិបាលរដ្ឋ និង ប្រធានសភា ថាពួកលោកនឹងធ្វើអ្វីៗគ្រប់បែបយ៉ាងដែលលោកអាចធ្វើទៅបាន ដើម្បីធ្វើយ៉ាងណាឲ្យច្បាប់យកពន្ធថ្លៃបារីអនុម័តទៅជាឯកច្ឆន្ទ នៅពេលដែលព្រឹទ្ធសភា និងសភា ត្រឡប់មកធ្វើការវិញនៅខែក្រោយ។ យើងខ្ញុំអរគុណចំពោះការគាំទ្រ និងការដឹកនាំ របស់ថ្នាក់ដឹកនាំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដែលមាន ចៅហ្វាយក្រុង និង ក្រុមប្រឹក្សាក្រុង ដល់ការខិតខំប្រឹងប្រែងនេះ។

តាមការថ្លឹងថ្លែងកត្តាទាំងនេះ យើងខ្ញុំបានសម្រេចថា ការបើកសាលាតាមពេលកំណត់ ជាមួយការកាត់បន្ថែមទាំងនេះ គឺជាការសម្រេចចិត្តដែលមិនសូវខូចប្រយោជន៍ដល់ សិស្សានុសិស្ស និងក្រុមគ្រួសារ។ ដើម្បីឲ្យស្របទៅតាមការខ្វះខាត យើងខ្ញុំបានរៀបចំការកាត់បន្ថយការបម្រើផ្សេងៗដូចតទៅនេះ៖

- សិស្សវិទ្យាល័យដែលរស់នៅពីរ (២) ម៉ាយល៍ ពីសាលា នឹងមិនទទួលជំនួយសម្រាប់យានជំនិះទេ (បង្កើនចម្ងាយពី ១,៥ ម៉ាយល៍)។ ដោយមូលហេតុនេះ សិស្សានុសិស្សរបស់ក្រសួង សាលាឆាទ័រ និងសាលាឯកជន ប្រហែល ៧,៥០០ នឹងមិនទទួលជំនួយសម្រាប់យានជំនិះតទៅទៀតទេ។

- សិស្សានុសិស្សប្រហែល៣០០នាក់ នឹងទទួលការប៉ះពាល់ដោយសារការកាត់បន្ថយការបម្រើក្នុងកម្មវិធីទៅកាន់ការបញ្ចប់ការសិក្សា ដែលបណ្តាលឲ្យមានឱកាសជ្រើសរើសកាន់តែតិចចំពោះកម្មវិធីដែលមានគុណភាពខ្ពស់ សម្រាប់សិស្សានុសិស្ស។
- បំបាត់ ការរៀបចំ និង ការហ្វឹកហ្វឺនផ្នែកការងារ មុនពេលសាលាបើក សម្រាប់គ្រូនៅសាលាដែលមានបញ្ហាខ្លាំងមួយចំនួនរបស់យើង - វិទ្យាស្ថានដែលសន្យាថានឹងផ្តល់ការអប់រំល្អ។
- សាលានឹងមិនសូវមានការសម្អាតញឹកញាប់ ហើយក៏មិនសូវមានសម្ភារៈសម្រាប់សម្អាត។ ការជួសជុលនៅសាលានឹងត្រូវពន្យាពេល។
- ក្រសួងនឹងមិនជួលប៉ូលីសសាលាដែលនៅមានកន្លែងទំនេរ កាត់បន្ថយចំនួនភ្នាក់ងារដែលជួយដល់ សន្តិសុខសាលា។
- ការកាត់បន្ថយបន្ថែមបុគ្គលិកនៅតាមការិយាល័យ នឹងបណ្តាលឲ្យមានការកាត់បន្ថយជំនួយដល់ សាលា និង ក្រុមគ្រួសារ ដោយផ្ទាល់។ ព័ត៌មានលម្អិតដែលទាក់ទងនឹងការកាត់បន្ថយនឹងប្រកាសនៅថ្ងៃក្រោយ នៅពេលដែលយើងខ្ញុំធ្វើការជាមួយបុគ្គលិករបស់យើង។

យើងខ្ញុំក៏បានធ្វើការសន្មត់ - ហើយនេះជាការសន្មត់ដែលស្ថិតនៅក្នុងភាពគ្រោះថ្នាក់បំផុត - ថា យើងខ្ញុំនឹងអាចចចារជាមួយក្រុមឈ្មួញសំខាន់ ក្នុងការកាត់បន្ថយតម្លៃ បានប្រាក់ចំណូលយ៉ាងច្រើនពីការលក់អាគារដែលនៅសល់ ហើយរក្សាការបង់ថ្លៃឲ្យសាលាឆាទ័ររបស់យើង តាមរយៈនៃការបង់ថ្លៃពីរដ្ឋ តាមកម្រិតកំណត់នៃការចុះឈ្មោះសិស្សឲ្យចូលរៀន។

ការកាត់បន្ថយដ៏ច្រើនលើសលប់ទៅលើកិច្ចការសំខាន់ៗរបស់យើង យើងអង្វរសុំ ក្រុមផ្តល់ប្រាក់ និង សហជីពផ្សេងៗ មួយចំនួន ឲ្យជួយទប់ស្កាត់ដល់ការខូចខាតបន្ថែមទៀត ដល់សាលា និង ការអប់រំរបស់សិស្សានុសិស្ស របស់យើង។

យើងអង្វរសុំឲ្យសមាជិករដ្ឋសភារបស់យើង អនុម័តច្បាប់យកពន្ធលើថ្លៃបារីសម្រាប់តែទីក្រុងហ្វីឡាដែលហ្វ្យា ឲ្យបានឆាប់បំផុត ដែលយើងសង្ឃឹមថាអាចនាំចូលនូវប្រាក់ចំណូលប្រហែលជា ៤៩ លានដុល្លារ នៅឆ្នាំនេះ បើសិនជាគេអនុវត្តនៅថ្ងៃទី១ ខែតុលា។ ការពន្យាពេលអនុញ្ញាតឲ្យយកពន្ធលើថ្លៃបារីនេះ អាចខាតបង់ប្រាក់ចំណូលរាប់លានដុល្លារ ក្នុងមួយខែៗ។

យើងអង្វរសុំឲ្យ សហជីពគ្រូបង្រៀននៃទីក្រុងហ្វីឡាដែលហ្វ្យា (PFT) យល់ព្រមកែប្រែអោយដូចក្រុមផ្សេងៗ ដែលបានយល់ព្រមឲ្យរួចមកហើយ ដូចជា នាយកសាលា ក្រុមកម្មករ និង បុគ្គលិកដែលគ្មានសហជីព។ យើងខ្ញុំមិនមែនសុំឲ្យកាត់បន្ថយប្រាក់ខែពី (PFT) នោះទេ ប៉ុន្តែយើងសុំឲ្យផ្លាស់ប្តូរអត្ថប្រយោជន៍ផ្សេងៗ ដែលអាចជួយយើងឲ្យផ្តល់ការបម្រើសំខាន់ៗឡើងវិញ នៅតាមសាលា។

បើសិនជា រដ្ឋ និង (PFT) មិនរកមធ្យោបាយដោះស្រាយប្រាក់ដែលនៅខ្វះខាតចំនួន ៨១ លានដុល្លារ ដូចបានប្រកាសនៅថ្ងៃនេះទេ នៅពាក់កណ្តាលខែតុលា យើងនឹងកាត់ថវិកាសាលាទាំងបង្ហំ ដែលអាចបង្កើនចំនួនសិស្សនៅក្នុងថ្នាក់ ហើយបង្កើនចំនួនថ្នាក់ដែលដាក់ចូលគ្នា ឬ «បំបែក» ថ្នាក់។

និយាយឲ្យច្បាស់ ការបង្គ្រប់ប្រាក់ដែលខ្វះចំនួន ៨១ លានដុល្លារ គឺគ្រាន់តែជួយឲ្យក្រសួងត្រឡប់ទៅជួយ ការខ្វះខាត និង ភាពមិនគ្រប់គ្រាន់ ដែលមានកាលពីឆ្នាំមុន។ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរនៅសាលារបស់យើង យើងត្រូវការប្រាក់ជំនួយថ្មី រួមទាំងរូបមន្តដ៏ត្រឹមត្រូវនៃប្រាក់ឧបត្ថម្ភ ពីរដ្ឋ និងការរៀបចំថ្លៃចំណាយដែលមានការទទួលខុសត្រូវ និងការកែសម្រួលអត្ថប្រយោជន៍របស់បុគ្គលិក ដែលហួសកាលកំណត់។

មនុស្សពេញវ័យមានអំណាចធ្វើឲ្យមានត្រឹមត្រូវ នូវអំពើខុសឆ្គងបានកើតមានឡើងដល់សិស្សានុសិស្ស និង សាលា របស់យើង។ ការផ្តល់ឲ្យក្មេងនូវការអប់រំល្អ ហើយមានគុណភាពខ្ពស់ មិនមែនគ្រាន់តែជាសិទ្ធិរបស់ពួកគេតែប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាកាតព្វកិច្ចនៃសីលធម៌របស់យើង។ ខ្ញុំសង្ឃឹមថាពលរដ្ឋនៅទីក្រុងហ្វីឡាដែលហ្វ្យាទាំងអស់ នឹងរួបរួមជាមួយក្រសួងអប់រំ ក្នុងការស្វែងរកអ្វីៗដែលល្អបំផុតសម្រាប់សិស្សានុសិស្ស។

ដោយសេចក្តីស្ម័គ្រស្មោះ



William R. Hite, Jr., Ed.D